PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី ១ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

PESTECH

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទីមួយ ឆ្នាំ ២០២៣ (លានរៀល) | ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ២៣៣ ៩២៣ | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ |
| បំណុលសរុប | | ១ ១២៣ ៥៦៩ | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ |
| មូលធនសរុប | | ១១០ ៣៥៤ | ១១០ ០១៦ | ៩៣ ៨៩៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទីមួយ ឆ្នាំ ២០២៣ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល)** |
| ចំណូលសរុប | | ៣២ ៧៥៦ | ៧៤ ១៥៧ | ៧៤ ៤៤៨ |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (៤ ៨៦៧) | ៥ ៤៨៧ | (១៨៨) |
| ចំណេញប្រតិបត្តិការ | | ២ ៤៥៩ | ៧ ៨៤៨ | ៦ ៧៨៦ |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | (៥ ៣៣២) | ៤ ៤៦៨ | (១ ២៩៥) |
| ចំណេញ/(ខាត)សរុបលម្អិត | | ៣៣៨ | ៦ ៣១១ | (៦៤៤) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីមួយ ឆ្នាំ ២០២៣** | **ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** |
| អនុបាតសាធនភាព | | (១,០១%) | ១,៦៨% | ២,៤០% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | (៨,២៥%) | ១៥,៩៥% | ៤៩,៩៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៤ | ០,៩៣ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៩៣ | ០,៩២ | ០,២៤ |
| | | **ត្រីមាសទីមួយ ឆ្នាំ ២០២៣** | **ត្រីមាសទីមួយ ឆ្នាំ ២០២២** | **ត្រីមាសទីមួយ ឆ្នាំ ២០២១** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,៤៣%) | ០,៣៧% | (០,១២%) |
| | អនុបាតចំណេញធៀបនឹងមូលធន | (៤,៨៣%) | ៤,០៦% | (១,៣៨%) |
| | អនុបាតគម្លាតចំណេញដុល | ១៩,៩៨% | ១៤,៧៩% | ១៣,៤៣% |
| | អនុបាតគម្លាតចំណេញភាព | (១៦,២៨%) | ៦,០៣% | (១,៧៤%) |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | (៧១,១៥) | ៥៩,៦២ | (១៧,៥៥) |

PESTECH

| | | | |
|---|---|---|---|
| អនុបាតលទ្ធភាពបង់ការប្រាក់ | ០,២៤ | ១,៤៦ | ០,៩៧ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន | គ្មាន |

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៥៥ ៦៣៤ លានរៀល (ឆ្នាំ ២០២២៖ ៤៣ ៨៨១ លានរៀល) និង កម្ចីរយៈពេលវែង មានចំនួន ៣៦៧ ៩០៥ លានរៀល គិតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២២ (ឆ្នាំ ២០២២៖ ៣៧២ ៦៩២ លានរៀល) ។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិកទាំងអស់

យើងបានឈានមកដល់ត្រីមាសទីមួយ (១) នៃការិយបរិច្ឆេទ ២០២៣ ដោយប្រឹងទប់ទល់នឹងភាពមិនអំណោយផលរបស់ទីផ្សារដែលបន្តមកពីការិយបរិច្ឆេទមុន។

ផលប៉ះពាល់អវិជ្ជមានដែលកើតឡើងបណ្តាលមកពីជម្លោះរាំរ៉ៃរវាងរុស្ស៊ីនិងអ៊ុយក្រែន ការដំឡើងអត្រាការប្រាក់ឥតឈប់ឈរ និងស្ថានភាពបិទខ្ទប់យ៉ាងយូរនៅក្នុងប្រទេសចិន មិនបានធូរស្រាលនោះទេក្នុងអំឡុងត្រីមាសទី១ នៃការិយបរិច្ឆេទ ២០២៣។ យើងនៅតែជួបប្រទះនឹងបញ្ហាក្នុងការរៀបចំភស្តុភារ ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ចលនាតម្លៃមិនសមហេតុផលនៃទំនិញនិងសម្ភារៈ និងការកើនឡើងនៃការចំណាយហិរញ្ញប្បទាន។

ដូច្នេះហើយ យើងបានសង្កេតឃើញលទ្ធផលហិរញ្ញវត្ថុធ្លាក់ចុះជាបន្តបន្ទាប់ក្នុងអំឡុងត្រីមាសនេះ ដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលយើងបានបញ្ជាក់ក្នុងអំឡុងត្រីមាសចុងក្រោយនៃការិយបរិច្ឆេទ ២០២២ យើងសង្ឃឹមថាលក្ខខណ្ឌទីផ្សារដែលមិនអំណោយផលនាពេលបច្ចុប្បន្នគឺមានលក្ខណៈជាបណ្តោះអាសន្ន។ យើងនឹងបន្តតស៊ូរហូតដល់ការិយបរិច្ឆេទ ២០២៣ ដោយខិតខំអស់ពីសមត្ថភាពដែលក្រុមការងារយើងអាចផ្តល់ឲ្យបានចំពេលមានកត្តាឥទ្ធិពលខាងក្រៅ ដែលអាចកំណត់សមិទ្ធិផលចុងក្រោយរបស់យើងនៅក្នុងការិយបរិច្ឆេទនេះ។

ផេសថិក ខេមបូឌា ម.ក នឹងនៅតែផ្តោតលើចក្ខុវិស័យរបស់ខ្លួនក្នុងការអភិវឌ្ឍខ្លួនឯងឲ្យកាន់តែរឹងមាំក្នុងនាមជាក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធថាមពលរឹកលូតលាស់នៅក្នុងប្រទេសកម្ពុជា ដែលបម្រើដល់មហាអនុតំបន់មេគង្គ។ យើងមានបំណងបង្កើតក្រុមការងារដែលមានមនុស្សពោរពេញដោយទេពកោសល្យក្នុងស្រុកដែលអាចជម្រុញក្រុមហ៊ុនឲ្យបណ្តាក់ទុនចូលទៅក្នុងឱកាសនានានៅក្នុងតំបន់ តំណាងឲ្យម៉ាកយីហោដែលអាចទុកចិត្តបាន មានប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការជម្រុញការអភិវឌ្ឍន៍ថាមពលប្រកបដោយនិរន្តរភាព។

ជាថ្មីម្តងទៀត យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ភាគហ៊ុន អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងារ ផេសថិក នៅប្រទេសកម្ពុជាសម្រាប់ការគាំទ្រឥតឈប់ឈរ ដែលជួយជំរុញក្រុមហ៊ុនឆ្ពោះទៅមុខមិនថាក្នុងកាលទេសណាក៏ដោយ។

សូមអរគុណ។

Paul Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

## សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

គោរពជូនដល់ភាគហ៊ុនិកទាំងអស់!

ជាអកុសល ដំណើរការអាជីវកម្ម ក្នុងអំឡុងត្រីមាសទីមួយនៃការិយបរិច្ឆេទ ២០២៣ មិនបាននាំមកនូវលទ្ធផលហិរញ្ញវត្ថុវិជ្ជមាន។

យើងនៅតែបន្តចំណាយប្រតិបត្តិការខ្ពស់ ដែលនាំឲ្យអត្រាប្រាក់ចំណេញប្រតិបត្តិការធ្លាក់ចុះប្រហែល ៧.៥%។ នោះ គួបផ្សំនឹងការចំណាយហិរញ្ញប្បទានខ្ពស់ បណ្តាលឲ្យបន្ទាត់ខាងក្រោមចុះបញ្ជីឱនភាពប្រហែល 1.3 លានដុល្លាអាមេរិច នៅក្នុង មាសទីមួយ (១) នៃការិយបរិច្ឆេទ ២០២៣ នេះ។

ត្រីមាសដែលកំពុងត្រួតពិនិត្យត្រូវបានគាំទ្រជាចម្បងដោយវឌ្ឍនភាពនៃគម្រោងខ្សែបញ្ជូន 500kV ពីភ្នំពេញទៅកម្ពុជា/ឡាវ រួមជាមួយគម្រោងខ្សែក្រោមដី 230kV ដែលផ្តល់មូលនិធិដោយ JICA ។ ក្រុមប្រតិបត្តិការ និងថែទាំបាននាំមកនូវចំណូលមូលដ្ឋាន ដែលជួយជំរុញក្រុមហ៊ុន។

ក្នុងអំឡុងឆ្នាំសារពើពន្ធដែលស្ថិតក្រោមការត្រួតពិនិត្យ ក្រុមវិស្វករ និងអ្នកដំឡើងរបស់យើងបានបញ្ចប់ដោយជោគជ័យនូវប្រព័ន្ធផលិតថាមពលអគ្គិសនីតាមដំបូល 750kWp សម្រាប់រោងចក្រនៅខេត្តកណ្តាល រួមជាមួយនឹងក្រុមហ៊ុន TotalEnergies ។ ផថខ មានបំណងបន្តកិច្ចខិតខំប្រឹងប្រែងពង្រីកក្នុងការផ្តល់ដំណោះស្រាយដែលអាចជឿទុកចិត្តបានសម្រាប់ដំបូលសូឡាដែលមានក្រឡាចត្រង្គដល់អតិថិជនឧស្សាហកម្មក្នុងប្រទេសកម្ពុជា។ នេះក៏ស្របតាមគោលបំណងរបស់ក្រុមក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ថាមពលប្រកបដោយនិរន្តរភាព ដើម្បីជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការរួមបញ្ចូលយ៉ាងសកម្មនូវធនធានថាមពលកកើតឡើងវិញទៅក្នុងល្បាយថាមពលរបស់ខ្លួន។

ផថខ បានចូលរួមក្នុងការដេញថ្លៃខ្សែបញ្ជូន 220kW និង 500kV នៅក្នុងប្រទេសអ៊ូសបេគីស្ថាន។ យើងសង្ឃឹមថាការប៉ុនប៉ងដេញថ្លៃនឹងចេញជាវិជ្ជមាន ដែលផ្តល់ឱ្យក្រុមហ៊ុននូវការបណ្តាក់ទុនលើកដំបូងរបស់ខ្លួនទៅកាន់តំបន់អាស៊ីកណ្តាល ដោយនាំចេញសេវាកម្មអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថាមពលកម្ពុជាទៅកាន់អន្តរជាតិ។

គាំទ្រដោយការរំពឹងទុកថ្មីនេះ ដោយមានសៀវភៅបញ្ជាទិញដ៏ច្រើននៅក្នុងដៃ អ្នកគ្រប់គ្រងរក្សានូវទស្សនៈវិជ្ជមានលើការអនុវត្តនាពេលអនាគតរបស់ក្រុមហ៊ុន ហើយបង្ហាញការដឹងគុណរបស់យើងចំពោះម្ចាស់ភាគហ៊ុន អតិថិជន អ្នកផ្គត់ផ្គង់ និងដៃគូ ក្រុមការងារ ជេសថិក សម្រាប់ទំនុកចិត្ត និងការគាំទ្រនៅក្នុង ផ្លូវនៃការអភិវឌ្ឍន៍របស់យើង។

សូមអរគុណ។

Han Fatt Juan

នាយកប្រតិបត្តិ

កាលបរិច្ឆេទ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

PESTECH

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..................... i

សមាសភាពក្រុមប្រឹក្សាភិបាល ..................... ii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..................... iii

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ ..................... iv

**ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី**

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី

ខ. សកម្មភាពអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖ ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម**

ក. លទ្ធផលប្រតិបត្តិការជីវកម្ម

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកឯករាជ្យ**

**ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន**

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

PESTECH

## ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | PESTECH (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH១០០០១៥០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី II ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជានិយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Paul Lim Pay Chuan |

### ខ. ប្រភេទអាជីវកម្ម

ផថខ បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("**O&M**") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

### គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

ពុំមានព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាសក្រោមការត្រួតពិនិត្យនោះទេ។

## ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការអាជីវកម្ម

### ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសក្រោមការត្រួតពិនិត្យដែលមានទឹកប្រាក់ចំនួន ២៩ ៣៦៩ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៧០ ៩៥៦ លានរៀល) ដែលស្មើនឹងប្រមាណ ៨៩,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៥,៧%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M") ការកត់ត្រាប្រាក់ចំណូល មានទឹកប្រាក់ចំនួន ៣ ៣៨៧ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លាអាមេរិច) ដែលស្មើនឹង ១០,៣% នៃចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ២០១ លានរៀល ឬ ៤,៣%)។

ក្នុងកំឡុងត្រីមាសនេះ សម្ព័ន្ធក្រុមហ៊ុនបានទទួលស្គាល់ចំណូលហិរញ្ញប្បទាន មានចំនួន ២ ៧២៨ លានរៀល (ត្រីមាសទីមួយ ឆ្នាំ ២០២២៖ ២ ៩៨៤ លានរៀល) សម្រាប់កិច្ចសន្យាជាក់លាក់ជាមួយអតិថិជន ស្របតាមការអនុលោមស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១៥ ("CIFRS") 15 ។ចំណូលហិរញ្ញប្បទានគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបនៃសម្ព័ន្ធ។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទីមួយ ឆ្នាំ ២០២៣ | | ត្រីមាសទីមួយ ឆ្នាំ ២០២២ | | ត្រីមាសទីមួយ ឆ្នាំ ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់បណ្តាញអគ្គីសនីនិងអនុស្ថានីយ៍ | ២៩ ៣៦៩ | ៨៩,៧ | ៧០ ៩៥៦ | ៩៥,៧ | ៧១ ២៣៨ | ៩៥,៧ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៣ ៣៨៧ | ១០,៣ | ៣ ២០១ | ៤,៣ | ៣ ២១០ | ៤,៣ |
| | **ប្រាក់ចំណូលសរុប** | **៣២ ៧៥៦** | **១០០,០** | **៧៤ ១៥៧** | **១០០,០** | **៧៤ ៤៤៨** | **១០០,០** |
| | ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៧២៨ | ១០០,០ | ២ ៩៨៤ | ១០០.០ | គ្មាន | គ្មាន |
| | **ប្រាក់ចំណូលសរុប** | **៣៥ ៤៨៤** | **១០០,០** | **៧៧ ១៤១** | **១០០,០** | **៧៤ ៤៤៨** | **១០០,០** |

## ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្មដោយសវនកម្មឯករាជ្យ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ រួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ៣២ ៧៥៦ លានរៀល ដោយថយចុះចំនួន ៤១ ៤០១ លានរៀល ឬ ៥៥,៨% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៧៤ ១៥៧ លានរៀល ។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យគឺបណ្តាលមកពីការបញ្ចប់នៃគម្រោងនៅបាវិតនាខែ មករា ឆ្នាំ ២០២២ ហើយមានការវិវឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាបដែលកំពុងដំណើរការបន្តបន្ទាប់រហូតដល់បញ្ចប់នៃវដ្តគម្រោង។

២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ដែលមានទឹកប្រាក់ចំនួន ២៩ ៣៦៩ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៧០ ៩៥៦ លានរៀល) ដែលស្មើនឹងប្រមាណ ៨៩,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៥,៧%) នៃចំណូលសរុប ។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ ("O&M") ការកត់ត្រាប្រាក់ចំណូលមានទឹកប្រាក់ចំនួន ៣ ៣៨៧ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លាអាមេរិច) ដែលស្មើនឹង ១០,៣% នៃចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ២០១ លានរៀល ឬ ៤,៣%)។

៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ២០,០% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនមានចំនួន ១៤,៨% ដោយកើនឡើងចំនួន ៥,២%។ សរុបមក ចំណេញដុលសម្រាប់រយៈពេលបច្ចុប្បន្នគឺស្ថិតនៅក្នុងការរំពឹងទុករបស់សម្ព័ន្ធក្រុមហ៊ុន។

៤. ការវិភាគ(ខាត)/ចំណេញមុនបង់ពន្ធ

ខាតមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ៤ ៨៦៧ លានរៀល បើប្រៀបធៀបទៅនឹងការចំណេញមុនពេលបង់ពន្ធមានចំនួន ៥ ៤៨៧ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ១០ ៣៥៤ លានរៀល ឬ ១៨៨,៧% ។ ខាតមុនបង់ពន្ធជាកត្តាចម្បងដែលធ្វើអោយថ្លៃដើមហិរញ្ញប្បទានខ្ពស់ជាងបើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

៥. ការវិភាគ(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ

ការខាតក្រោយដកពន្ធនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ៥ ៣៣២ លានរៀល បើប្រៀបធៀបទៅនឹងចំណេញក្រោយដកពន្ធមានចំនួន ៤ ៤៦៨ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះមានចំនួន ៩ ៨០០ លានរៀល ឬ ២១៩,៣% ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយ ដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ៣២ ៧៥៦ លានរៀល ដោយថយចុះចំនួន ៤១ ៤០១ លានរៀល ឬ ៥៥,៨% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៧៤ ១៥៧ លានរៀល ។ បម្រែបម្រួលនៃចំណូលសរុបបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញគឺបណ្តាលមកពីការបញ្ចប់គម្រោងនៅបាវិត នាខែ មករា ឆ្នាំ២០២២ ហើយមានការវិវឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាប ដែលត្រូវបានដំណើរការជាបន្តបន្ទាប់រហូតដល់ការបញ្ចប់នៃវគ្គគម្រោង។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

## ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ១៧% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៥,០% (គិតត្រឹមថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០២២ ប្រភព៖ *ធនាគារអភិវឌ្ឍន៍អាស៊ី៖ ADB រក្សាការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ ដោយបានកែសម្រួលការព្យាករសម្រាប់ឆ្នាំ២០២៣* ) ដែលបានបង្កផលប៉ះពាល់ប្រហែល ០,៨៥% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ រាល់ចំណាយប្រតិបត្តិការទាំងអស់ មានតម្លៃថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះនោះទេ។

PESTECH

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ២ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២២

បានអាន និងឯកភាព

**ហត្ថលេខា**

ព្រះរាជាណាចក្រកម្ពុជា ផេសធិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល